# ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត

## វគ្គ៖ លោកគ្រូអារទឹកក្រូច




FIRST FINANCE




Image are Generated with AI


ចា៎ ជម្រាបសួរ លោកគ្រូ ខ្ញុំហ្នឹង ហើយ **កូលាប**
សឿនផង លោកគ្រូ! មកមុនណាត់ទៀត! សូមអញ្ជើញអង្គុយសិន លោកគ្រូ


ខ្ញុំអញ្ជើញ លោកគ្រូមក ដើម្បី ប្រឹក្សារឿងស្នើ កម្ចី ៩,០០០ ដុល្លារ ។ យករយៈពេល ១០ឆ្នាំ បានអត់? លោកគ្រូ
អធ្យាស្រ័យ អ្នកបងបម្រុងយក ធ្វើអ្វីខ្លះដែរ?


**៨ពាន់** យក រៀបបន្ទប់ខាងក្រោម និងបន្ទប់ទឹក
សល់ **១ពាន់** ទៀតទុកប្រើថ្ងៃក្រោយ
ខ្ញុំអាចសុំដឹងពីចំណូល ចំណាយក្នុងគ្រួសារ និងព័ត៌មានផ្សេងទៀតបានទេ?
បានតើស៎! ក្នុង ១ខែ ទូរទាត់ចំណាយហើយ ខ្ញុំនៅសល់ប្រហែល **៤០០ ដុល្លារ**


បើតាម
ព័ត៌មានដែលផ្ដល់ឲ្យ
អ្នកបងអាចស្នើបាន **៨ពាន់**
បង់ប្រហែលជា **២០៤ដុល្លារ**
ក្នុង ១ខែ អាចយករយៈពេល
ត្រឹម ៥ឆ្នាំបានហើយ


ចុះអាម៉េច មិនឲ្យ
គ្រប់ ៩,០០០?
លទ្ធភាពខ្ញុំមានតើស៎?!
ខ្ញុំអាចបង់បានដល់
៤០០ ក្នុង១ខែ


អ្នកបងស្នើតែកម្ចីដែលចាំបាច់បានហើយ ព្រោះប្រាក់កម្ចីត្រូវចំណាយលើការប្រាក់។ **កុំយកទុកនៅខ្លួនអីបើមិនទាន់ត្រូវការប្រើ**
ខ្ញុំដឹងថាអ្នកបងអាចសល់ ៤០០ ក្នុង ១ខែ ក៏ប៉ុន្តែអ្នកបងក៏ត្រូវការ **១ចំណែក ដើម្បីសន្សំទុកប្រើប្រាស់ក្នុងគ្រាអាសន្ន**ផងដែរ មិនអាចយកមកបង់កម្ចីទាំងអស់នោះទេ




សូមតាមដានភាគបន្ត នៅសប្តាហ៍ក្រោយ


សូមអធ្យាស្រ័យផង ប្រសិនបើខ្ញុំ
សួរនាំច្រើនពេក ពេលដាក់ពាក្យ
ស្នើកម្ចីម្តងៗ ការពិតគឺជាបំណងល្អទេ
ខ្ចីប្រកបដោយការទទួលខុសត្រូវ
• សូមស្នើកម្ចីសម្រាប់កិច្ចការចាំបាច់ និង
ទៅតាមលទ្ធភាពសង
• មានផែនការច្បាស់លាស់មុនពេលស្នើកម្ចី
• ស្វែងយល់ពីអត្រាការប្រាក់ តម្លៃសេវា
លក្ខខណ្ឌពិន័យ បង់ថ្លៃសេវា... និងលក្ខខណ្ឌ
ផ្សេងៗទៀតឲ្យបានច្បាស់លាស់ មុនពេល
ចុះកិច្ចសន្យា និងដកប្រាក់ ។
• ចំនួនបង់កម្ចីប្រចាំខែ គប្បីមិនត្រូវលើសពី
៦០% នៃចំនួនសុទ្ធប្រចាំខែ ។

**ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ត** ជាកម្រងរឿងខ្លីៗ ដែលនិយាយពីជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមួយស្ថិតក្នុងជីវភាពមធ្យម ។ នៅក្នុងវគ្គនីមួយៗនៃរឿងនេះ ត្រូវបានបញ្ចូលសារអប់រំខ្លីៗ ជូន ដល់អ្នកអាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រង និងរៀបចំផែនការហិរញ្ញវត្ថុក្នុងគ្រួសារដំណើរការដាក់ស្នើរកម្ចីផលិតផលកម្ចី និងសារអប់រំផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធិភាព ។

យើងខ្ញុំស្វាគមន៍ទទួលយកគន្លឹះផ្សេងៗទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ តាមការស្នើរសុំពីប្រិយមិត្តដើម្បីបញ្ចូលទៅក្នុងសាច់រឿង ។

ដូច្នេះប្រសិនបើប្រិយមិត្តមាន គន្លឹះដែលល្អៗ អាចផ្ញើរមកកាន់ទំព័រ Facebook របស់
ហ្វឹស ហ្វាយនែន ឬតាមរយអ៉ីម៉ែល
infor@firstfiance.com.kh យើងខ្ញុំនឹងត្រូវពិនិត្យហើយដាក់ជូន ប្រសិនបើយល់ឃើញថា អត្ថបទឬគន្លឹះនោះមានប្រយោជន៍ដល់ប្រិយមិត្តអ្នកអានផ្សេងទៀត ។

នាំមកជូនដោយ

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
## ហ្វឹស ហ្វាយនែន ភីអិលស៊ី

FIRST FINANCE

គេហទំព័រ ហ្វឹស ហ្វាយនែន
www.firstfinance.com.kh